# ការវិភាគលើការអនុវត្តគោលនយោបាយ
# ទេសន្តរប្រវេសន៍ការងារ
# សម្រាប់ប្រទេសកម្ពុជា
# ឆ្នាំ២០១៦-២០១៧

ខែវិច្ឆិកា ឆ្នាំ២០១៧

Australian Aid

International Labour Organization

កម្មវិធីត្រីកោណក្នុងតំបន់អាស៊ាន នៃអង្គការអន្តរជាតិខាងការងារ (ILO)

ខែវិច្ឆិកា ឆ្នាំ ២០១៧

# មាតិកា


ពាក្យកាត់ ........ 4

សេចក្តីផ្តើម ........ 5

វិធីសាស្ត្រ ........ 5

ដែនកំណត់នៃវិធីសាស្ត្រ ........ 6

របកគំហើញសំខាន់ៗ ........ 7

ការវិភាគការអនុវត្តគោលនយោបាយ ........ 9

ការអនុវត្តល្អ ........ 12

បញ្ហាប្រឈមចំពោះការអនុវត្តគោលនយោបាយ ........ 14

អនុសាសន៍សម្រាប់ការអនុវត្តនាពេលអនាគត ........ 15

បង្កើនកិច្ចសហប្រតិបត្តិការអន្តរក្រសួង ........ 15

ការដាក់បញ្ចូលការសិក្សា និងរបកគំហើញថ្មី ទៅតាមការចាំបាច់ ........ 15

បន្តការអភិវឌ្ឍគោលនយោបាយសំខាន់ៗ ........ 16

ថវិកា ........ 16

ការពិនិត្យតាមដាន និងវាយតម្លៃ ........ 16

ផែនការអទិភាពសម្រាប់ឆ្នាំ២០១៧-២០១៨ ........ 17

សកម្មភាពគោលនយោបាយ ........ 17

ការបណ្តុះបណ្តាលជំនាញ ....................................................................................................18
ថ្លៃចំណាយសម្រាប់ការធ្វើទេសន្តរប្រវេសន៍ការងារ.........................................................................19
ការពិនិត្យតាមដាន និងវាយតម្លៃ..........................................................................................16
ការវិលត្រលប់ និងការធ្វើសមាហរណ៍កម្ម ..................................................................................20

## ពាក្យកាត់

| | |
|---|---|
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ILO | អង្គការអន្តរជាតិខាងការងារ |
| IOM | អង្គការទេសន្តរប្រវេសន៍អន្តរជាតិ |
| MOFA | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MOLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOWA | ក្រសួងកិច្ចការនារី |
| MOSAVY | ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងស្តារយុវនីតិសម្បទា |
| NCCT | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស |
| PDOLVT | មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| LMPC | គោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| TVET | បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស |
| UNACT | ភ្នាក់ងារអង្គការសហប្រជាជាតិសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស |

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាដំណាក់កាលទី២កាលពីខែធ្នូឆ្នាំ២០១៤។ គោលនយោបាយនេះត្រូវបានបង្កើតឡើងដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(MoLVT)ដោយមានការគាំទ្រពីកម្មវិធីត្រីកោណតំបន់អាស៊ាន (TRIANGLE in ASEAN Programme) របស់អង្គការអន្តរជាតិខាងការងារ (ILO) សម្រាប់រយៈពេលអនុវត្តចាប់ពី ខែមករា ឆ្នាំ២០១៥ ដល់ខែធ្នូ ឆ្នាំ២០១៨។ ការវិភាគលើការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារ សម្រាប់ប្រទេសកម្ពុជាលើកទី១បានធ្វើឡើងនៅខែសីហាឆ្នាំ២០១៦។ការវិភាគលើការអនុវត្តគោលនយោបាយឡើងវិញលើកទី២នេះគឺដើម្បីធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពនានានៃការអនុវត្តគោលនយោបាយបញ្ហាប្រឈមនានានិងកំនត់សកម្មភាពអទិភាពដើម្បីអនុវត្តបន្តក្នុងឆ្នាំ២០១៨។ ដូចនេះនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) បានរៀបចំសិក្ខាសាលាត្រីភាគីបូកដើម្បីពិនិត្យការអនុវត្តន៍គោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជានិងបានបង្កើតផែនការសកម្មភាពមួយសម្រាប់អនុវត្តក្នុងឆ្នាំ២០១៨ដែលមានជាជំហ៊ានតាមលំដាប់ដូចខាងក្រោម:

## វិធីសាស្រ្ត

យុទ្ធសាស្រ្តគោលនយោបាយមាន៦ផ្នែកធំៗសម្រាប់ការអនុវត្ត រួមមានៈក្របខ័ណ្ឌអន្តរជាតិក្របខ័ណ្ឌស្ថាប័នការគ្រប់គ្រងលើការងារជ្រើសរើសពលករនិងផ្តល់ការងារសេវាកម្មគាំទ្រការធ្វើទេសន្តរប្រវេសន៍នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍ ការធ្វើមាតុភូមិនិវត្ត និងការធ្វើសមាហរណកម្ម។ គោលនយោបាយនេះ ត្រូវបានដាក់ឲ្យអនុវត្តនៅខែធ្នូ ឆ្នាំ២០១៤ ក្នុងគោលបំណងអនុវត្តសម្រាប់រយៈពេលប្រមាណ៤ឆ្នាំដែលមានសកម្មភាពមួយចំនួនសំរាប់អនុវត្តរយៈពេលខ្លី(១-២ឆ្នាំ)និងសកម្មភាពខ្លះទៀតសំរាប់អនុវត្តរយៈពេលវែង (៣-៤ឆ្នាំ) ។ តាមរយៈការកំណត់សកម្មភាពដែលកំពុងអនុវត្តដោយភាគីពាក់ព័ន្ធសំខាន់ៗការវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនេះត្រូវបានធ្វើឡើងសម្រាប់ឆ្នាំ២០១៧ ដោយកត់សម្គាល់

ពីការវាស់វែងលើសកម្មភាពគោលដៅនីមួយៗនៃគោលនយោបាយនេះថាជាសកម្មភាព "ស្របតាមផែនការដែលបាន គ្រោងទុក" នៅពេលដែលសកម្មភាពទាំងនោះបានបញ្ចប់ ថាជាសកម្មភាព"កំពុងរីកចម្រើន"សម្រាប់សកម្មភាពទាំងឡាយណាដែលបានបង្ហាញឬ បញ្ជាក់ថាសកម្មភាពកំពុងដំណើរការឆ្ពោះទៅរកការបញ្ចប់សកម្មភាពឬថាសកម្មភាពនេះ នឹងត្រូវ បានបញ្ចប់ក្នុងកំឡុងឬមុនខែធ្នូឆ្នាំ២០១៨និងថាជាសកម្មភាព"មិនសម្រេចគោលដៅ "សម្រាប់សកម្មភាពទាំងឡាយណាដែលមិនមានការបញ្ជាក់ដែលថាសកម្មភាពនោះកំពុងដំ ណើរការ។ ឯកសារលំអិតនៃគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេស កម្ពុជាបញ្ជីឈ្មោះដៃគូរពាក់ព័ន្ធនិងវឌ្ឍនភាពសំខាន់ៗដែលបានកត់ត្រាមាននៅក្នុងឧបសម្ព័ន្ធ ទី១។

## ដែនកំណត់នៃវិធីសាស្រ្ត

ដែនកំណត់នៃវិធីសាស្រ្តនេះ អាចមានការប្រែប្រួល។ ក្នុងករណីខ្លះសកម្មភាពគោល នយោបាយមិនត្រូវបានបឹទបញ្ចប់ទេដោយសារតែមានទិសដៅនៃគោលនយោបាយថ្មីៗត្រូវ បានបង្កើតឡើង។ឧទាហរណ៍ដូចជាការបង្កើតឡើងនូវសេវាកម្មច្រកចេញចូលតែមួយតាម បណ្តាខេត្តមួយចំនួនដើម្បីផ្តល់ឬចេញឯកសារទាំងឡាយណាដែលជាតម្រូវការសម្រាប់ការធ្វើ ទេសន្តរប្រវេសន៍ការងារជាទៀងទាត់នៅតាមបណ្តាខេត្តដែលមានអត្រាប្រជាពលរដ្ឋធ្វើទេស ន្តរប្រវេសន៍ខ្ពស់ដែលការងារនេះត្រូវបានកំណត់ថាជាសកម្មភាពគោលនយោបាយថ្មីមួយ។ ផ្ទុយទៅវិញក៏មានការសម្រេចមួយទៀតថាជាការប្រសើរគួរតែមានការពិភាក្សាពិគ្រោះយោប ល់ជាមួយរដ្ឋាភិបាលថៃឡង់ដ៏ដើម្បីបង្កើតមជ្ឈមណ្ឌលមួយចំនួនក្នុងប្រទេសថៃឡង់ដ៏ព្រោះ ថាពលករទេសន្តរប្រវេសន៍មួយចំនួនមិនវិលត្រលប់មកឬស្នាក់នៅក្នុងប្រទេសកម្ពុជាគ្រប់ពេ លនោះទេហើយពួកគេមួយចំនួនក៏មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំឯកសារទាំងនោះ ដែរ។

លើសពីនេះទៀតបញ្ហាលំបាកផ្នែកភាសាទំនាក់ទំនងក៏គម្បីពិចារណាក្នុងការពិគ្រោះយោបល់ ឲ្យបានស៊ីជម្រៅជាមួយអ្នកពាក់ព័ន្ធទាំងអស់ផងដែរដើម្បីបង្កើតសកម្មភាពនានានិងអនុវត្តនៅ ប្រទេសកម្ពុជា។

ដូច្នេះវិធីសាស្ត្រនេះអាចចាត់ទុកថាជាការវាស់វែងមួយដែលមានកម្រិតខ្ពស់សម្រាប់ការវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនេះ។

## របកគំហើញសំខាន់ៗ

ខុសគ្នាពីឆ្នាំ២០១៦អ្នកពាក់ព័ន្ធដែលត្រូវបានសម្ភាសន៍នៅឆ្នាំ២០១៧ មានការយល់ដឹងច្រើនអំពីគោលនយោបាយទេសន្តរប្រវេសន៍ការងារសំរាប់ប្រទេសកម្ពុជា។ ដោយកត់សំគាល់ឃើញថាមានក្រសួង/ស្ថាប័ននានាបានចូលរួមធ្វើសកម្មភាពហើយបានសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តសកម្មភាពរបស់ពួកគេ។ ទោះជាយ៉ាងណាក្តីក៏នៅមានខ្វះចន្លោះការសម្របសម្រួលលើសកម្មភាពមួយចំនួននិងបញ្ហាប្រឈមជាមួយនឹងការត្រួតគ្នាលើសកម្មភាពមួយចំនួននិងការទទួលខុសត្រូវត្រួតគ្នានៅក្នុងអាណត្តិនៃក្រសួង/ស្ថាប័នខ្លះរបស់ពួកគេ។

គ្រប់ក្រសួង/ស្ថាប័នទាំងអស់ដែលបានសម្ភាសន៍បញ្ជាក់ថាក្រសួង/ស្ថាប័នរបស់ពួកគេមានធាតុខ្លះៗនៃគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជានៅក្នុងផែនការយុទ្ធសាស្ត្រឬឯកសារស្រាវជ្រាវឬគោលការណ៍ណែនាំឬក្នុងអាណត្តិរបស់ក្រសួង/ស្ថាប័នឬអនុគណៈកម្មការរបស់ពួកគេ។ នេះគឺជាការសមស្របបំផុតទោះជាយ៉ាងណាក៏ដោយបុគ្គលិក/មន្ត្រីដែលបានសម្ភាសន៍ហាក់ដូចជាមានភាពមិនច្បាស់លាស់ខ្លះៗអំពីទំនាក់ទំនងនិងតួនាទីរាយការណ៍សម្រាប់ការអនុវត្តគោលនយោបាយនីមួយៗឲ្យបានត្រឹមត្រូវរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយមន្ត្រីទាំងនោះចាត់ទុកថាការងាររបស់ពួកគេពាក់ព័ន្ធនឹងវិស័យទេសន្តរប្រវេសន៍ការងារគឺជាអាទិភាពហើយពួកគេចង់ធានាឲ្យមានការអនុវត្តដ៏ល្អបំផុត។

ជារឿយៗការខ្វះធនធាននិងសមត្ថភាពត្រូវបានកំណត់ថាជាបញ្ហាប្រឈម។ ដៃគូអភិវឌ្ឍន៍ អង្គការផ្តល់ សេវាតាមសហគមន៍ និងទីភ្នាក់ងារជ្រើសរើសឯកជន ក៏បានរាយការណ៍អំពីការរួមចំណែកដ៏សំខាន់របស់ពួកគេក្នុងការអនុវត្តគោលនយោបាយនេះផងដែរ។នេះជាសញ្ញាល្អសម្រាប់ការអនុវត្តគោលនយោបាយនេះប្រកបដោយជោគជ័យ។ខណៈដែលការរីកចម្រើនចេញពីការអនុវត្តគោលនយោបាយនេះត្រូវបានបង្ហាញឲ្យឃើញច្បាស់ភាគច្រើននៃការអនុវត្ត

សកម្មភាពគោលនយោបាយនេះនៅតែពឹងពាក់លើម្ចាស់ជំនួយហើយក៏នៅខ្វះការសម្របស
ម្រួលជាទូទៅបើទោះបីជាមានភាពល្អប្រសើរឡើងច្រើនជាងកាលពីឆ្នាំមុនក៏ដោយ។

# ការវិភាគការអនុវត្តគោលនយោបាយ

រូបភាពទី ១: វឌ្ឍនភាពសកម្មភាពនៃគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០១៥-២០១៨ តាមផ្នែកនៃការអនុវត្តន៍ (២០១៧)




គោលនយោបាយនេះមានសកម្មភាពចំនួន៩៤នៅក្រោមគោលដៅនៃគោលនយោបាយចំនួន១៧(សូមមើលឧបសម្ព័ន្ធទី១)ដែលភាគច្រើនត្រូវបានបែងចែកនិងអនុវត្តដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(MOLVT)ដែលជាក្រសួងទទួលខុសត្រូវសំខាន់របស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយនេះ។

លទ្ធផលដែលសម្រេចបានរហូតដល់ ខែវិច្ឆិកា ឆ្នាំ២០១៧ (មើលរូបភាពទី១) បង្ហាញពីការរីកចំរើននិងលទ្ធផលសំខាន់ៗដែលកំពុងដំណើរការអនុវត្តក្នុងផ្នែកទាំង៦ដើម្បីសម្រេចផែនការនេះត្រឹមបំណាច់ឆ្នាំ២០១៨។នៅក្នុងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧សកម្មភាពបន្ថែមមួយចំនួនត្រូវបានដាក់បញ្ចូលដូច្នេះលទ្ធផលដែលបានប្រៀបធៀបរវាងឆ្នាំ២០១៧និងឆ្នាំ២០១៦គឺមិនដូចគ្នាទាំងស្រុងនោះទេ។

នៅពេលធ្វើការប្រៀបធៀបទៅនឹងវឌ្ឍនភាពនានាដែលបានកត់ត្រានៅខែសីហា ឆ្នាំ២០១៦(សូមមើលរូបភាពទី២)ការរីកចម្រើនគួរឱ្យកត់សម្គាល់នៅក្នុងផ្នែកខ្លះៗនៃការអនុវត្ត គោលនយោបាយនេះក្នុងឆ្នាំ២០១៧មានដូចខាងក្រោម:

- នៅក្នុងក្របខ័ណ្ឌអន្តរជាតិ ៨៥% នៃសកម្មភាពកំពុងមានការរីកចម្រើន ឬស្របតាមផែនការដែលបានគ្រោងទុក។
- នៅក្នុងសកម្មភាពក្របខ័ណ្ឌស្ថាប័ន ៨៦% នៃសកម្មភាពកំពុងមានការរីកចម្រើន ឬស្របតាមផែនការដែលបានគ្រោងទុក។
- ក្នុងការត្រួតពិនិត្យការជ្រើសរើសការគ្រប់គ្រងនិងការផ្តល់ការងារ ៧០%កំពុងមានការរីកចម្រើន ឬស្របតាមផែនការដែលបានគ្រោងទុក។
- នៅក្នុងសេវាកម្មគាំទ្រ ៧៧%នៃសកម្មភាពកំពុងមានការរីកចម្រើនឬស្របតាមផែនការ ដែលបានគ្រោងទុក។
- ក្នុងការធ្វើទេសន្តរប្រវេសន៍ការងារក្នុងរបៀបវារៈអភិវឌ្ឍន៍ ៦២% នៃសកម្មភាពកំពុងមាន ការរីកចម្រើន និង
- ក្នុងការធ្វើមាតុភូមិនិវត្ត ៥០% កំពុងមានការរីកចម្រើន។

ដៃគូអភិវឌ្ឍនិងអង្គការសង្គមស៊ីវិលគឺជាដៃគូសំខាន់ក្នុងការរួមចំណែកអនុវត្តសកម្មភាពនៃ គោលនយោបាយនេះជាមួយរដ្ឋាភិបាល។ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(MOLVT) បានរៀបចំនិងដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ ទេសន្តរប្រវេសន៍និងការអនុវត្ត គោលនយោបាយនេះទទួលបានជោគជ័យ។ សេចក្តីសង្ខេបលម្អិតគឺមាននៅក្នុងឧបសម្ព័ន្ធទី ១

រូបភាពទី ២: វឌ្ឍនភាពនៃសកម្មភាពដែលបានអនុវត្តនៃគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០១៥- ២០១៨ តាមផ្នែកនៃការអនុវត្ត (២០១៦)




ផ្នែកសំខាន់ៗនៃការអនុវត្តដែលមានភាពប្រសើរឡើងនៅឆ្នាំ២០១៦ រួមមាន:

- ក្របខ័ណ្ឌស្ថាប័នបច្ចុប្បន្នមាន១៤%ដែលមិនស្ថិតលើគោលដៅដែលមានការថយចុះ១៥% ពីឆ្នាំ២០១៦ ។
- ការត្រួតពិនិត្យការជ្រើសរើសពលករនិងការផ្តល់ការងារ គឺមាន ៣១% ដែលមិនស្ថិតលើគោលដៅដែលមានការថយចុះ ៣២% ពីឆ្នាំ ២០១៦ និង
- សេវាកម្មគាំទ្រគឺមាន ២៣% នៃគោលដៅមិនស្ថិតលើគោលដៅដែលថយចុះ ៣% ពីឆ្នាំ ២០១៦។

រូបភាពទី ៣: ការប្រៀបធៀបសកម្មភាពដែលបានអនុវត្តនៃគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៧




ការប្រៀបធៀបជារួមរវាងឆ្នាំ២០១៦ និងឆ្នាំ២០១៧ បង្ហាញថាសកម្មភាពថយចុះ ១០% គឺមិនស្ថិតលើគោលដៅដោយមានការកើនឡើងនៃសកម្មភាព ១០% កំពុងរីកចំរើន។

សកម្មភាពសរុបចំនួន៦% ត្រូវបានបំពេញយ៉ាងពេញលេញស្របតាមផែនការដែលបានគ្រោងទុក (បញ្ចប់) ។

## ការអនុវត្តល្អ

- តួអង្គសំខាន់ៗទាំងអស់ដែលបានសម្ភាស៍មានការយល់ដឹងកាន់តែច្រើនឡើងអំពីគោលនយោបាយ និងតួនាទីរបស់ពួកគេនៅក្នុងការរួមចំណែក អនុវត្តជាងការបង្ហាញនៅឆ្នាំ២០១៦។
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) បានទំនាក់ទំនងនិងធ្វើការងារដោយផ្ទាល់ជាមួយមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត(PDOLVT)មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍(MRC)ហាជីពនិងដៃគូសង្គមដើម្បីបង្កើតនិងដំណើរការយន្តការបណ្តឹងទាមទារសំណងសម្រាប់ពលករទេសន្តរប្រវេសន៍ទៀងទាត់និងសម្រាប់ពលករទេសន្តរប្រវេសន៍មិនទៀងទាត់ជាមួយនឹងការទទួលបានសំណងកំរិតខ្ពស់
- មានការកើនឡើងនូវភ័ស្តុតាងដែលបាននិងកំពង់ផ្តល់ព័ត៌មានដល់ការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា។នេះរួមបញ្ចូលទាំងការសិក្សាស្រាវ

ជ្រាវការស្ទង់មតិនៃថ្នាក់តំបន់នៃការចាប់ផ្ដើមរបស់គម្រោងTRIANGLEនៃអង្គការILO និងគម្រោង PROMISE នៃអង្គការIOM ក្រោមប្រធានបទ ភាពប្រឈម និងសំណាង និងការវាយតម្លៃតម្រូវការទីផ្សារការងារប្រទេសថៃឡង់ដ៏ទាក់ទងនឹងការអភិវឌ្ឍជំនាញសម្រាប់ពលករទេសន្តរប្រវេសន៍ការវាយតម្លៃពីប្រសិទ្ធភាពនៃការអនុវត្តយន្តការបណ្ដឹងសម្រាប់ពលករពលករទេសន្តរប្រវេសន៍ការងារទទួលបានសំណងនិងយុត្តិធមនិនៅប្រទេសកម្ពុជានិងប្រទេសក្នុងតំបន់អាសីអាគ្នេយ៍។ការរៀនសូត្រពីការអនុវត្តគោលនយោបាយនេះបានផ្ដល់ព័ត៌មានអំពីអាទិភាពនានា និងការអនុវត្តគោលនយោបាយនាពេលអនាគត។

- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (MOLVT) កំពុងសហការជាមួយក្រសួងព័ត៌មាន និងបានផ្សព្វផ្សាយលិខិតដែលចេញដោយក្រសួងទាំងពីរ ដល់មន្ទីរការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងមន្ទីព័ត៌មានស្ដីពីការផ្សព្វផ្សាយនិងការជ្រើសរើសពលករប្រកបដោយក្រមសីលធមិនិងតម្រូវឲ្យអង្គភាពសាពត៌មានរដ្ឋនិងឯកជនដូចជាវិទ្យុទូរ ទស្សន៍ចូលរួមទប់ស្កាត់ការផ្សព្វផ្សាយពត៌មានពាណិជ្ជកម្មដែលមិនត្រឹមត្រូវឬបោកប្រាស់និងទីភ្នាក់ងារជ្រើសរើសឯកជនដែលមិនបានចុះបញ្ជីរជាមួយក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ(MOLVT)បានចូលរួមក្នុងកម្រិតអាស៊ានតាមរយៈវេទិកាអាស៊ានស្ដីពីទេសន្តរប្រវេសន៍ការងារហើយកំពុងលើកកម្ពស់ឲ្យមានក្របខ័ណ្ឌការពារសិទ្ធិពលករកាន់តែប្រសើរឡើង និងយន្តការដោះស្រាយវិវាទ។
- គោលការណ៍ទូទៅនិងគោលការណ៍ណែនាំប្រតិបត្តិការសម្រាប់ការជ្រើសរើសប្រកបដោយភាពយុត្តិធម៌របស់អង្គការ ILO ត្រូវបានបកប្រែជាភាសាខ្មែរនិងផ្សព្វផ្សាយ។ ការជ្រើសរើសពលករប្រកបដោយភាពយុត្តិធម៌បានបង្ហាញពីភាពរីកចម្រើនគួរឲ្យកត់សម្គាល់នៅក្នុងសកម្មភាពដែលកំពុងមានការរីកចម្រើន
- ការផ្សព្វផ្សាយអំពីចំណាកស្រុកដើម្បីការងារប្រកបដោយសុវត្ថិភាពបង្កើនការយល់ដឹងដល់សាធារណៈជនត្រូវបានធ្វើឡើងយ៉ាងទូលំទូលាយទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ទោះបីជាមិនទាន់មានការសម្រប សម្រួលពេញលេញក៏ដោយ)។

- វគ្គបណ្តុះបណ្តាលតម្រង់ទិសមុនពេលចេញដំណើរដល់ពលករដែលបានរៀបចំឡើងដោយទីភ្នាក់ងារជ្រើសរើសឯកជន និងសមាគមភ្នាក់ជ្រើសរើសពលករកម្ពុជា (ACRA) ។
- ការបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ(TVET)កំពុងផ្តោតលើជំនាញនិងផ្នែកសំខាន់ៗមួយចំនួនទៀតដល់យុវជនទូទៅនិងយុវជនដែលមានសក្តានុពលក្នុងការធ្វើចំណាកស្រុក ការវិលត្រលប់ និងការធ្វើសមាហរណកម្ម ។

## បញ្ហាប្រឈមចំពោះការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍សម្រាប់ប្រទេសកម្ពុជា

- សកម្មភាពអនុវត្តលើផ្នែកទេសន្តរប្រវេសន៍ការងារសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមនៅតែជាវិស័យដែលមានការអភិវឌ្ឍន៍តិចតួចនៅឡើយ។នេះអាចបណ្តាលមកពីសកម្មភាពប្រឈមមួយចំនួនជាពិសេសកិច្ចចរចារជាមួយប្រទេសគោលដៅជាមួយស្ថាប័នហិរញ្ញវត្ថុនិងទិដ្ឋភាពមួយចំនួននៃកម្មវិធីវិលត្រលប់និងការធ្វើសមាហរណកម្មដែលទាមទារឲ្យមានការចូលរួមពីក្រសួង/ស្ថាប័នច្រើនជាងមួយហើយកិច្ចសហប្រតិបត្តិការអន្តរក្រសួងស្តីពីការអនុវត្តគោលនយោបាយនេះមិនទាន់ដល់កម្រិតខ្ពស់នោះឡើយ។ម្យ៉ាងទៀតការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយមិនទាន់ត្រូវបានប្រមូលផ្តុំឲ្យបានគ្រប់គ្រាន់នៅឡើយនៅក្នុងវិស័យនេះ។
- ខណៈពេលដែលគោលនយោបាយនេះបានដាក់ឲ្យអនុវត្តជាក់លាក់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT)ហើយក៏ដោយ ក៏នៅតែចាំបាច់មានវិធានការបន្ថែមទៀតដើម្បីធ្វើឲ្យមានអនុស្សារណៈយោគយល់គ្នា (MOU) កិច្ចសន្យាការងារ (employment contract) និងការអនុវត្តគោលនយោបាយអាទិភាពផ្សេងៗទៀតផងដែរ។
- ការបញ្ជាក់អំពីការចំណាយលើការធ្វើទេសន្តរប្រវេសន៍ការងារក៏ជាបញ្ហាអាទិភាពមួយដែលត្រូវដោះស្រាយខណៈពេលដែលប្រទេសផ្សេងៗមានការចំណាយផ្សេងៗគ្នានោះគឺប្រទេសកម្ពុជាគម្បីមានគោលនយោបាយមួយចាំបាច់ដើម្បីបញ្ជាក់ការចំណាយសមរម្យសម្រាប់ពលករទេសន្តរប្រវេសន៍ការងារ។

- ការពឹងផ្អែកខ្ពស់លើការផ្ដល់មូលនិធិពីម្ចាស់ជំនួយមានការប្រឈមនិងគំរាមកំហែងដល់និរន្តរភាពនៃសកម្មភាពដែលកំពុងអនុវត្តហើយវាមានន័យថាសកម្មភាពផ្សេងទៀតអាចនឹងមិនត្រូវបានអនុវត្ត។
- ព្រំដែនគោករបស់ប្រទេសកម្ពុជាជាប់ជាមួយប្រទេសថៃឡង់ដ៏យ៉ាងវែងរួមជាមួយនឹងតម្លៃខ្ពស់សម្រាប់ការធ្វើទេសន្តរប្រវេសន៍ការងារជាប្រចាំមានន័យថាអត្រាទេសន្តរប្រវេសន៍ការងារមិនទៀងទាត់នៅតែខ្ពស់ជាងការធ្វើទេសន្តរប្រវេសន៍ការងារទៀងទាត់។
- មានការព្រួយបារម្ភថ្មីៗដែលត្រូវបានលើកឡើងដូចជាផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់កុមារ និង/ឬសមាជិកគ្រួសារផ្សេងទៀត។

## អនុសាសន៍សម្រាប់ការអនុវត្តនាពេលអនាគត

ជំហានបន្ទាប់ដែលបានព្រមព្រៀងគ្នា ក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីបូក នោះមានដូចខាងក្រោម:

### បង្កើនកិច្ចសហប្រតិបត្តិការអន្តរក្រសួង

- ដោយសារសកម្មភាពគោលនយោបាយមួយចំនួនជាពិសេសការចរចាជាមួយបណ្ដាប្រទេសគោលដៅក្នុងការរៀបចំនិងអនុវត្តអនុស្សារណៈយោគយល់គ្នា(MOU) ការចរចាជាមួយក្រសួងហិរញ្ញវត្ថុនិងទិដ្ឋភាពមួយចំនួននៃកម្មវិធីវិលត្រលប់និងការធ្វើសមាហរណកម្មតម្រូវឲ្យមានការចូលរួមក្រសួង/ស្ថាប័នច្រើនជាងមួយការបង្កើនកិច្ចសហប្រតិបត្តិការអន្តរក្រសួងនឹងធានាថាលទ្ធផលនៃការអនុវត្តជាវិជ្ជមានបានកើតឡើង។ការងារនេះអាចត្រូវបានសម្របសម្រួលនៅក្នុងក្រុមការងាររទេសន្តរប្រវេសន៍ឬសម្របសម្រួលជាលក្ខណៈទ្វេភាគី។

### ការដាក់បញ្ចូលសកម្មភាពថ្មីៗមេរៀនពីការអនុវត្តគោលនយោបាយនិងការបង្កើតទស្សនទានថ្មីៗតាមតម្រូវការចាំបាច់

- ការសិក្សាស្រាវជ្រាវការផ្ដល់ពត៍មាននិងការវិភាគថ្មីៗគួរត្រូវបានបញ្ចូលគ្នាឲ្យបានសមស្របដើម្បីរួមចំណែកក្នុងការធ្វើគោលនយោបាយថ្មីៗនិងអាទិភាពចំបងៗ។

- កំណត់បញ្ហាថ្មីៗសម្រាប់ធ្វើការសិក្សាបន្ថែមមានដូចជា(កុមារដែលត្រូវបានគ្រួសារចាកចោល)ការធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវថ្មីសម្រាប់ការផ្តល់សច្ចាប័នអនុសញ្ញាលេខ១៨៩)

## បន្តជំរុញការអភិវឌ្ឍគោលនយោបាយសំខាន់ៗ

- ធ្វើការបញ្ជាក់ពីគោលការចំណាយលើការធ្វើទេសន្តរប្រវេសន៍ការងារនិងគួររៀបចំឲ្យមានការចំណាយនេះដែលមានលក្ខណស្តង់ដារមួយសម្រាប់ប្រទេសកម្ពុជា
- គម្បីពិចារណាកាផ្តល់សច្ចាប័ណអនុសញ្ញាលេខ១៨៩(លក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ)របស់អង្គការអន្តរជាតិខាងការងារILOនិងធ្វើប្រកាសថ្មីស្តីពីការប្រើប្រាស់ប្រាក់ធានាសម្រាប់ពលករនៅពេលពួកគេមានបញ្ហា ឬត្រូវការជំនួយណាមួយ

## ថវិកា

- ដោយសារការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសសកម្ពុជាជាច្រើនត្រូវ ពឹងផ្អែកលើមូនិធិពីម្ចាស់ជំនួយ ការបង្កើនកិច្ចសហប្រតិបត្តិការលើធនធានបច្ចេកទេសនិងហិរញ្ញវត្ថុរបស់ម្ចាស់ជំនួយដើម្បីសម្រេចបានលទ្ធផលរួមអាចទទួលបានសមិទ្ធិផលជាអតិបរិមានៃសកម្មភាពដែលបានអនុវត្ត។
- ការវិភាជធនធាន(ធនធានមនុស្សនិងហិរញ្ញវត្ថុ)របស់រដ្ឋាភិបាលនៅគ្រប់កម្រិតនៃការគ្រប់គ្រងការបញ្ជូនពលករទៅធ្វើការនៅឯបរទេសគម្បីពិនិត្យឡើងវិញនិងការប្រើប្រាស់ថវិកាជាតិ និងដើម្បីផ្លះបញ្ចាំងពីការតាំងចិត្តកាន់តែខ្លាំងក្លារបស់រដ្ឋាភិបាល និងរួមចំណែកដល់ការធ្វើទេសន្តរប្រវេសន៍ការងារទៅក្នុងការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា។
- ផែនការអនុវត្តន៍គោលនយោបាយទេសន្តរប្រវេសន៍ការងារក៏គួរតែស្របតាមផែនការថវិកាប្រចាំឆ្នាំ ដែលត្រូវបានបិទនៅក្នុងខែកក្កដាជារៀងរាល់ឆ្នាំ។

## ពិនិត្យតាមដាន និងវាយតម្លៃ

- ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃគួរធានាថាភាគីពាក់ព័ន្ធទាំងអស់យល់ច្បាស់អំពីកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលកិច្ចការតួនាទីការទទួលខុសត្រូវដែលត្រូវបានផ្តល់ឲ្យ

ពួកគេក្នុងការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជានិងគួរទទួលបាននូវធនធាន បច្ចេកទេស និងហិរញ្ញវត្ថុដើម្បីអនុវត្តការងារទាំងនេះផងដែរ។

## ផែនការអទិភាពម្រាប់ការអនុវត្តក្នុងឆ្នាំ២០១៨

- ផែនការអទិភាព៥ត្រូវបានកំណត់ដើម្បីអនុវត្តនៅក្នុងឆ្នាំ២០១៨នេះរួមមាន ១)សកម្មភាពគោលនយោបាយ ២)ការបណ្តុះបណ្តាលជំនាញ ៣)ថ្លៃចំណាយលើការធ្វើទេសន្តរប្រវេសន៍ ៤)ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងទី៥)កម្មវិធីវិលត្រលប់និងសមាហរណកម្ម។

## សកម្មភាពគោលនយោបាយ

ក្រុមពិភាក្សាបានផ្តោតលើចំនុចអទិភាពមួយចំនួនដូចជាក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) ពិភាក្សាជាមួយពីភ្នាក់ងារជ្រើសរើសឯកជន អ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត រួមជាមួយរដ្ឋាភិបាលប្រទេសទទួលពលករ អំពីលទ្ធភាព ដែលអាចផ្ទេរថវិការបស់ពលករទេសន្តរប្រវេសន៍មកប្រទេសកម្ពុជាវិញដោយផ្តោតជា សំខាន់លើកិច្ចការពារសង្គមនិងសំណងទូទាត់សំរាប់ពលករដែលនឹងត្រូវទទួលបាន។

អនុសាសន៍ក្រុមពិភាក្សាក៏បានលើកឡើងផងដែរពាក់ព័ន្ធមន្ត្រីកុងស៊ុល្យគប្បីទទួលបានជំនាញបណ្តុះបណ្តាលជាក់លាក់ (ដោយយោងទៅលើអនុក្រិត្យលេខ១៩០) ការដាក់ពិន័យឬដាក់ទោសប្រឆាំងនឹងទីភ្នាក់ជ្រើសរើសឯកជនណាដែលមិនបានអនុវត្តន៍តាមគោលការណ៍ណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(MOLVT)

និងគប្បីអនុវត្តឲ្យបានសមស្របផងដែរការចុះធ្វើអធិការកិច្ចការងារលើទីភ្នាក់ងារជ្រើសរើសឯកជន និងក្នុងរោងចក្រនៅប្រទេសនទីដៅគប្បីអនុវត្តអោយបានម៉ឹងមាត់ផងដែរប្រព័ន្ធវាយតំលៃសំរាប់ត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសឯកជនគប្បីដាក់ឲ្យដំណើរការ

បន្តចូលរួមនៅក្នុងក្របខណ្ឌអាស៊ានដើម្បីពិភាក្សាអំពីកិច្ចគាំពារសង្គម និងលទ្ធភាពការផ្ទេរប្រាក់របស់ពលករទេសន្តរប្រវេសន៍មកប្រទេសកម្ពុជាវិញដោយតម្រូវឲ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយមូលនិធិសន្តិសុខសង្គម អនុសាសន៍ក៏បានលើកឡើងផងដែរដល់ក្រសួងការងារ

និងបណ្តុះបណ្តាលវិជ្ជាជីវៈ(MOLVT)បន្តអនុវត្តផែនទីបង្ហាញផ្លូវដើម្បីឈានទៅដល់ការផ្តល់សច្ចាប័នអនុសញ្ញាលេខ១៨៩និងពិនិត្យឡើងវិញនៃការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជានិងបន្តកែសម្រួលគោលនយាបាយនេះ ដើម្បីឲ្យស្របទៅនឹងការប្រែប្រួលថ្មីៗនៅក្នុងកំរិតថ្នាក់តំបន់និងពិភពលោកក្រោយពីឆ្នាំ២០១៨។

## ការបណ្តុះបណ្តាលជំនាញ

ក្រុមពិភាក្សាបានកំណត់ពីសារៈសំខាន់នៃការទទួលបានឱកាសនៃការបណ្តុះបណ្តាលនិងការទទួលស្គាល់ជំនាញគឺជាជាអទិភាពមួយដែលគម្បីត្រូវដោះស្រាយ។ អនុសាសន៍ក៏បានស្នើរឡើងផងដែរដោយផ្តោតទៅលើការផ្សព្វផ្សាយពត៌មានការបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ឲ្យបានទូលំទូលាយតាមតែអាចធ្វើទៅបាននិងធ្វើឲ្យប្រាកដថាសកម្មភាពបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ឆ្លើយតបទៅនឹងគោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ(TVET) ឆ្នាំ២០១៧-ឆ្នាំ២០២៥។ ឧទាហរណ៍ការបណ្តុះបណ្តាលជំនាញផ្នែកទុនគម្បី ត្រូវបានដោះស្រាយ ប្រភពហិរញ្ញវត្ថុគម្បីត្រូវបានវិភាជពីថវិការជាតិ ការរួមចំណែករបស់វិស័យឯកជននិងការកសាងសមត្ថភាពរបស់វិទ្យាស្ថានបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) និងវិទ្យាស្ថានបណ្តុះបណ្តាលពាក់ព័ន្ធនានា (ដោយសារតែសមត្ថភាពរបស់វិទ្យាស្ថានបណ្តុះបណ្តាលមួយចំនួននូវមានកំរិត)។

គប្បីពិចារណាលើមាត្រា៩នៃអនុស្សារណៈយោគយល់គ្នា(MOU) រវាងប្រទេសកម្ពុជានិងប្រទេសថៃដែលតម្រូវឲ្យភាគីទាំងពីរធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាដែលបានកំណត់ឡើងជាចំនុចសំខាន់។ដោយរាប់បញ្ចូលទាំងការធ្វើការវាយតម្លៃទីផ្សារការងារដើម្បីស្វែងយល់និងរកឲ្យឃើញនៃចំនុចស៊ីង្វាក់គ្នានូវជំនាញដែលត្រូវផ្គត់ផ្គង់និងឲ្យស្របតាមតម្រូវការទីផ្សារការងារនៅប្រទេសថៃឡង់ដ៏និងដើម្បីរកឲ្យឃើញនូវចំនុចចន្លោះប្រហោងនិងដាក់ចេញនូវយុទ្ធសាស្រ្តកសាងសមត្ថភាពដល់ពលករទេស្តរប្រវេសន៍ឲ្យបានត្រឹមត្រូវនិងសមស្របដើម្បីឆ្លើយតបតម្រូវការទីផ្សារការងារក្នុងវិស័យនេះ។

វិស័យផ្សេងៗទៀតក៏បានកត់សំគាល់ផងដែរដើម្បីធ្វើអោយប្រាកដថា

ការបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ(TVET)គម្បីស្របគ្នាជាមួយនឹងគោលនយោបាយពាក់ព័ន្ធផ្សេងទៀតការទទួលស្គាល់ជំនាញដោយរាប់បញ្ចូលទាំងជំនាញនិងបទពិសោធន៍ដែលពលករបានទទួលតាមរយៈការងារដែលបានបំពេញនិងដាក់ចេញនូវកម្មវិធីធ្វើមាតុភូមិនិវត្តន៍/វិលត្រលប់សំរាប់ពលករទេសន្តរប្រវេសន៍។

## ថ្លៃចំណាយសម្រាប់ការធ្វើទេសន្តរប្រវេសន៍ការងារ

ក្រុមពិភាក្សាបានប៉ាន់ប្រមាណថ្លៃលើការចំណាយការធ្វើទេសន្តរប្រវេសន៍សរុបជាង ១៦០០ដុល្លាអាមេរិកសំរាប់ពលករម្នាក់ដើម្បីធ្វើទេសន្តរប្រវេសន៍ដោយទៀងទាត់។ តួលេខនេះបានរាប់បញ្ចូលទាំងថ្លៃចំណាយលើការធ្វើដំណើរចំណាយលើការត្រួតពិនិត្យសុខភាព ចំណាយលើការបណ្តុះបណ្តាល ចំណាយលើទិដ្ឋាការ ចំណាយលើប័ណ្ណការងារ ចំណាយលើការស្នាក់នៅ និងការចំណាយពាក់ព័ន្ធផ្សេងៗទៀតមានដូចជាថ្លៃចំណាយទៅលើមេខ្យល់ជាដើម។ ជាក់ស្តែងថ្លៃចំណាយទាំងនេះគឺខុសគ្នាឬប្រែប្រួលទៅតាមតំបន់។ ក្រុមពិភាក្សាក៏បានលើកឡើងផងដែរអំពីគោលការណ៍គ្រឹះនៃថ្លៃចំណាយដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិខាងការងារ(ILO)លេខ១៨១ដែលបានកំណត់ថាគ្មានការចំណាយណាមួយត្រូវបានធ្វើឡើងដោយពលករទេសន្តរប្រវេសន៍នោះទេ។អ្នកពាក់ព័ន្ធផ្សេងៗទៀតក៏បានលើកឡើងផងដែរគប្បីបង្កើតអោយមានគោលនយោបាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងលើថ្លៃចំណាយនេះអោយបានប្រសើរផងដែរ។

## ការត្រួតពិនិត្រតាមដាន និងវាយតំលៃ

ក្រុមពិភាក្សាបានកំណត់ថាក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(MOLVT) គឺជាស្ថាប័នដ៏សំខាន់ក្នុងការទទួលខុសត្រូវលើការត្រួតពិនិត្យតាមដាននិងវាយតំលៃការអនុវត្តន៍គោលនយោបាយនេះក្រុមពិភាក្សាក៏បានស្នើរឡើងផងដែរដើម្បីបង្កើតក្រុមការងារមួយដើម្បីតាមដានត្រួតពិនិត្យលើការអនុវត្តគោលនយោបាយនេះក្រុមពិភាក្សាក៏បានទទួលស្គាល់ផងដែរអំពីសារៈសំខាន់សុច្ចនាករនិងចំនុចដៅគួរមានភាពបត់បែនខ្លះដោយហេតុថាស្ថានភាពមានការផ្លាស់ប្តូរនិងសុច្ចនាករខ្លះទៀតមិនសមស្របឬមិនអាចសម្រេចបានទាន់

ពេលវេលា និងថាគួរធ្វើការកែសម្រួលឡើងវិញ ដើម្បីឲ្យមានភាពងាយស្រួលនិងអាចសម្រេចបាន។សុច្ឆនាករនោះគួរដាក់បញ្ចូលខេត្តគោលដៅជាពិសេសខេត្តដែលបានអនុវត្តន៍យុទ្ធការបណ្តឹង។

## កម្មវិធីវិលត្រឡប់ និងការធ្វើសមាហរណកម្ម

ក្រុមនេះបានកំណត់ពីសារៈសំខាន់សេវាគាំទ្រនានាដល់ពលករដែលបានវិលត្រលប់មកវិញ អនុសាសន៍ក៏បានលើកឡើងផងដែរគប្បីផ្តោតទៅលើការផ្តល់ជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈដល់ពលករដែលបានវិលត្រលប់។

ក្រុមពិភាក្សាក៏បានទទួលស្គាល់ផងដែរថាសេវាគាំទ្រមានសារៈសំខាន់សំរាប់ពលករក្នុងការវិលត្រលប់ដោយរួមមានៈ សេវាសង្គម សេវាសុខភាព សេវាបណ្តុះបណ្តាលជំនាញ និងសេវាផ្នែកហិរញ្ញវត្ថុឬសេដ្ឋកិច្ច។

ក្រុមពិភាក្សាក៏បានទទួលស្គាល់ភាពប្រឈមសំខាន់ៗផងដែរគឺពលករខ្វះការយល់ដឹង (ការអប់រំរបស់ពួកគេបានតិចតួច)ដែលអាចរារាំងដល់ការចូលរួមរបស់ពួកគេនៅក្នុងកម្មវិធីបណ្តុះបណ្តាលនានា។ម្យ៉ាងវិញទៀតពលករខ្លះក៏មិនមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលឬក៏ចូលរួមជាមួយកម្មវិធីអាហាររូបករណ៍ផ្សេងៗដែលធ្វើឲ្យពលករខកខានឬមិនបានរកចំនួលផ្សេងៗដោយសារការចូលរួមរបស់ពួកគេនេះ។